ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈ

# នៃ

# សមាគមអ្នកសាងសង់កម្ពុជា

( ស.ស.ក )

ឆ្នាំ ២០១១

# ជំពូកទី ១

## អំពីឈ្មោះ អាសយដ្ឋាន អត្តសញ្ញាណ ត្រា និងនិមិត្តសញ្ញារបស់សមាគម

**ប្រការ ១.** អំពីឈ្មោះសមាគម

សមាគមនេះមានឈ្មោះជាភាសាខ្មែរថា " **សមាគមអ្នកសាងសង់កម្ពុជា** " សរសេរអក្សរកាត់ (ស.ស.ក) និង មានឈ្មោះជាភាសាអង់គ្លេសថា " **CAMBODIA CONSTRUCTORS ASSOCIATION** " សរសេរអក្សរកាត់ (C.C.A) ។

**ប្រការ ២.** អំពីអាសយដ្ឋានសមាគម

សមាគមអ្នកសាងសង់កម្ពុជា(ស.ស.ក)មានទីស្នាក់ការនៅផ្ទះលេខ ៣១៥ ភូមិ ១ ផ្លូវ ១១០ កែងផ្លូវ ៩៣ សង្កាត់ វត្តភ្នំ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ។ ទីស្នាក់ការសមាគមអាចផ្លាស់ ប្តូរក្នុងករណីចាំបាច់ តាមសេចក្តីសម្រេចរបស់មហាសន្និបាតសមាគម ។

**ប្រការ ៣.** អំពីអត្តសញ្ញាណសមាគម

សមាគមអ្នកសាងសង់កម្ពុជា គឺជាសមាគមក្រៅរដ្ឋាភិបាល មិនធ្វើនយោបាយ មិនរកផលចំណេញ និងអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា គឺជាសមាគមបំរើវិស័យសំណង់ និងអ្នកសាងសង់ ។

**ប្រការ ៤.** អំពីនិមិត្តសញ្ញា និងត្រាសមាគម

សមាគមអ្នកសាងសង់កម្ពុជា មាននិមិត្តសញ្ញាដូចខាងក្រោម ៖

- មានរាងជារង្វង់មូលពីរជាន់ដែលរង្វង់ខាងក្នុងមានផ្ទៃពណ៌ក្រហម
- ចន្លោះពីរង្វង់ខាងក្នុងទៅរង្វង់ខាងក្រៅ មានផ្ទៃពណ៌ខៀវទឹកប៊ិចក្រមៅ
- នៅក្នុងរង្វង់ខាងក្រៅផ្នែកខាងលើ សរសេរអក្សរថា **ព្រះរាជាណាចក្រកម្ពុជា** (ពណ៌ទឹកមាស) និងផ្នែកខាងក្រោមសរសេរថា **សមាគមអ្នកសាងសង់កម្ពុជា** (ពណ៌ទឹកមាស)
- នៅផ្ទៃកណ្តាលរង្វង់មូលខាងក្នុងមានរូបសញ្ញាហោជាងដំបូលផ្ទះដែលមានសញ្ញាសំគាល់រចនាបថក្បាច់បុរាណខ្មែរ គឺមានរូបនាគមួយគូរវិញកន្ទុយចូលគ្នាបះឡើងលើជាផ្លូងមួយ (ពណ៌ទឹកមាស) ហើយផ្ទៃខាងក្នុងរង្វង់នេះដែរ ផ្នែកខាងលើមានសរសេរជាអក្សរអង់គ្លេសថា **KINGDOM OF CAMBODIA** (ពណ៌ទឹកមាស) និងផ្នែកខាងក្រោមមានសរសេរជាអក្សរអង់គ្លេសថា **CAMBODIA CONSTRUCTORS ASSOCIATION** (ពណ៌ទឹកមាស) និងនៅខាងក្រោមរូបសញ្ញាហោជាងដំបូលផ្ទះដែលមាន សញ្ញាសំគាល់រចនាបថក្បាច់បុរាណខ្មែរ មានសរសេរអក្សរកាត់ថា **ស.ស.ក** និង **C.C.A** (ពណ៌ ទឹកមាស )។

- ត្រារបស់សមាគមមានសណ្ឋានជារង្វង់មូលទំហំ៣៩ម.មផ្ទៃចំកណ្តាលមានរូបសញ្ញាហោជាងដំបូលផ្ទះដែលមានអត្ថន័យនិងខ្លឹមសារដូចខាងលើ ហើយផ្ទៃខាងក្នុងរង្វង់ផ្នែកខាងក្រោមរូបសញ្ញាមានសរសេរអក្សរកាត់ថា ស.ស.ក និង **C.C.A** ហើយត្រានេះត្រូវប្រើទឹកល័ក្តពណ៌ខៀវ ។

# ជំពូកទី ២

## ចក្ខុវិស័យ គោលបំណង បេសកកម្ម និងសកម្មភាព

**ប្រការ ៥.** ចក្ខុវិស័យរបស់សមាគម

ចក្ខុវិស័យរបស់សមាគមអ្នកសាងសង់កម្ពុជា ( ស.ស.ក ) គឺសំដៅ :

១- ប្រែក្លាយឧស្សាហកម្មសំណង់របស់ជាតិ ជាឧស្សាហកម្មប្រកបដោយទំនុកចិត្ត ផលិតភាព គណនេយ្យភាព និងការប្រកួតប្រជែង ទាំងក្នុងទីផ្សារជាតិ និងអន្តរជាតិ ។

២- ធ្វើឱ្យសមាជិកទាំងអស់របស់សមាគមអ្នកសាងសង់កម្ពុជា ក្លាយជាអ្នកសាងសង់មានលំដាប់ស្តង់ដារខ្ពស់ និងចំណាត់ថ្នាក់លំដាប់អន្តរជាតិ ។

៣- ផ្តល់ឱ្យសមាគមអ្នកសាងសង់កម្ពុជានូវតួនាទីជាអង្គការជួយសម្របសម្រួលទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងផ្នែកឯកជនក្នុងវិស័យសំណង់ ដើម្បីផ្តល់នូវផលប្រយោជន៍ ដល់ឧស្សាហកម្មសំណង់ ។

**ប្រការ ៦.** គោលដៅ និងគោលបំណងរបស់សមាគមមានដូចតទៅ ៖

១- អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិជាមួយដៃគូក្រុមហ៊ុនសាងសង់ទាំងក្នុងប្រទេស នៅក្នុងតំបន់អាស៊ាន និងអន្តរជាតិ។

២- ចូលរួមក្នុងសហព័ន្ធអ្នកសាងសង់អាស៊ាន និងសមាគមអ្នកសាងសង់អន្តរជាតិ ផ្សេងទៀត និងស្វែងរកការគាំទ្រពាក់ព័ន្ធនឹងការសាងសង់ និងការអភិវឌ្ឍន៍ វិស័យសំណង់ ។

៣- លើកកំពស់កិច្ចសហការល្អ និងការគោរពគ្នាក្នុងវិជ្ជាជីវៈព្រមទាំងលើកទឹកចិត្តឲ្យមានទំនាក់ទំនងប្រកបដោយសុខដុមនីយកម្មរវាងបុគ្គលក្រុមហ៊ុនសារជីវកម្មដែលធ្វើអាជីវកម្មជា អ្នកអភិវឌ្ឍវិស័យសំណង់ ។

៤- ជំរុញកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និតរវាងក្រុមហ៊ុនសាងសង់ក្នុងស្រុកជាពិសេសជាមួយក្រុមហ៊ុនសាងសង់ក្នុងតំបន់អាស៊ាន និងសមាគមអ្នកសាងសង់អន្តរជាតិផ្សេងៗ ។

៥- រៀបចំគាំទ្រចូលរួមកម្មវិធីអប់រំ ឬការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការសាងសង់ ការអភិវឌ្ឍការងារស្ថាបត្យកម្ម វិស្វកម្ម នគរូបនីយកម្ម និងវិស័យពាណិជ្ជកម្មផ្សេងទៀត។

៦- ជំរុញឲ្យមានការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងអង្គភាពសមាគមអ្នកសាងសង់អន្តរជាតិនានាក្នុងការសាងសង់ និងការអភិវឌ្ឍន៍ វិស័យសំណង់។

៧- ការពារផលប្រយោជន៍ស្របច្បាប់របស់សមាជិកសមាគម ជាពិសេសក្នុងការចរចារ ឬពិភាក្សាជាមួយក្រសួងស្ថាប័នរដ្ឋ ព្រមទាំងជាមួយសមាគមវិស្វករ ស្ថាបត្យករ អ្នកវាស់



នាយកដ្ឋានកិច្ចការនយោបាយ

វែង និង/ឬ អ្នកជំនាញការផ្សេងទៀតលើទិដ្ឋភាពទាក់ទងនឹងគោលនយោបាយហិរញ្ញវត្ថុ បទប្ប- ញ្ញត្តិ ស្តង់ដារ បច្ចេកទេស នីតិវិធី ឬដំណើរការនៃការចុះបញ្ជីពាក់ព័ន្ធនឹងការសាងសង់ និងការអភិវឌ្ឍន៍វិស័យសំណង់។

៨- ធ្វើជាតំណាងនៅក្នុងគណៈកម្មាធិការក្រុមប្រឹក្សាភិបាលដែលបង្កើតដោយរាជរដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនឹងការសាងសង់ ការអភិវឌ្ឍន៍ ការងារស្ថាបត្យកម្ម ជាដើម។

៩- បោះពុម្ព ផ្សព្វផ្សាយ និងចែកចាយនូវឯកសារ ព្រឹត្តប័ត្រនានាដែលទាក់ទងនឹងសមាគម និង/ឬទាក់ទងនឹងការសាងសង់ និងការអភិវឌ្ឍន៍ វិស័យសំណង់។

១០- ផ្តល់សិទ្ធិអំណាចដល់ប្រធាន និងអគ្គលេខាធិការសមាគមដើម្បីធ្វើជាតំណាងរបស់សមាគមជាសាធារណៈ និងទំនាក់ទំនងជាមួយសារព័ត៌មាននៅគ្រប់បញ្ហាពាក់ព័ន្ធនឹងសមាគម។

១១- ផ្តល់ប្រាក់ឧបត្ថម្ភអាហារូបករណ៍សិក្សាដល់បុគ្គលទាំងឡាយណាដែលមានលក្ខណៈសម្បត្តិល្អប្រសើរ ដោយប្រើប្រាស់ថវិការបស់សមាគម។

## ប្រការ ៧. បេសកកម្មរបស់សមាគម

សមាគមអ្នកសាងសង់កម្ពុជា ( ស.ស.ក ) មានបេសកកម្មដូចតទៅ ៖

១- ផ្តួចផ្តើមរៀបចំក្រមសីលធម៌សម្រាប់អ្នកសាងសង់

២- បង្កើតភាពជាដៃគូ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងអ្នកសាងសង់

៣- លើកទឹកចិត្ត និងគាំទ្រសមត្ថភាពជំនាញដល់សមាជិកសមាគម

៤ - ខិតខំប្រឹងប្រែងដើម្បីគាំពារដល់សមាជិកសមាគម

៥- លើកកម្ពស់នូវការរីកចំរើននៃឧស្សាហកម្មសំណង់។

## ប្រការ ៨ . អំពីសកម្មភាពសមាគម

ដើម្បីសម្រេចបានគោលបំណងនិងគោលដៅដូចមានចែងក្នុងប្រការ៥ខាងលើសមាគមមានសកម្មភាព៖

១- ទិញ សាងសង់ ឬជួលអចលនវត្ថុ ឬទីតាំងសម្រាប់ធ្វើជាទីស្នាក់ការរបស់សមាគម និងជ្រើសរើស ឬជួលបុគ្គលិកសម្រាប់បំរើការងារសមាគម ។

២-គ្រប់គ្រងកែលម្អអភិវឌ្ឍន៍ និងប្រើប្រាស់អចលនវត្ថុ ឬបុគ្គលិកទាំងនោះ ជួល ធ្វើអំណោយ ដាក់បញ្ចាំ ដាក់ហ៊ីប៉ូតែក នូវអចលនវត្ថុរបស់សមាគម ដើម្បីបានជាផលប្រយោជន៍របស់សមាគម ។

៣-ទទួលនូវរាល់អំណោយនានាដែលជូនសមាគមដោយសមាជិកមួយ ឬច្រើនរបស់សមា- គម ឬដោយបុគ្គលដ៏ទៃណាមួយ ។

៤-ប្រតិបត្តិឬបំពេញមុខងារផ្សេងទៀតដូចជាការសាងសង់ដែលបំរើផលប្រយោជន៍របស់សមាគម ។

៥-ផ្តល់ការគាំទ្រផ្នែកសម្ភារ: ឬគាំទ្រក្នុងទម្រង់ផ្សេងទៀតដល់សមាជិកសមាគមក្នុងកំរិតកំណត់ដោយគណ:កម្មាធិការប្រតិបត្តិរបស់សមាគម ។

៦-ផ្តល់នូវពានរង្វាន់ ប្រាក់ឧបត្ថម្ភ អាហារូបករណ៍ដល់បុគ្គលិកទាំងឡាយដែលមានលក្ខណ:សម្បត្តិល្អប្រសើរ ដោយប្រើប្រាស់ថវិកាសមាគម។

៧-ជួយគាំទ្រដល់សមាជិករបស់សមាគមតាមការស្នើសុំរបស់សមាជិកពាក់ព័ន្ធ នឹងការចរចារឬទំនាក់ទំនងជាមួយភាគីទី៣ ក្នុងការសាងសង់ ការអភិវឌ្ឍន៍ និងការងារស្ថាបត្យកម្ម។

៨-រៀបចំសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាល ដោយមានការគាំទ្របច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬពីស្ថាប័នផ្សេងទៀតដល់សមាជិក បុគ្គលិក កម្មករ អ្នកបច្ចេកទេសពាក់ព័ន្ធនឹងការងារសាងសង់ និងការអភិវឌ្ឍន៍វិស័យសំណង់។

៩-ចូលរួមសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាសមាជិកអាស៊ាន និងអន្តរជាតិ ។

# ជំពូកទី ៣
# អំពីសមាជិកភាពរបស់សមាគម

## ផ្នែកទី ១
## អំពីការចូលជាសមាជិកសមាគម

**ប្រការ ៩ .** អំពីសមាជិកសមាគម

សហគ្រាស ក្រុមហ៊ុនប្រកបអាជីវកម្មសាងសង់ សិក្សាគម្រោងប្លង់ និងអង្គភាពផ្សេងទៀតដែលបំរើឱ្យវិស័យសំណង់ទាំងអស់មានជាអាទ៍ ក្រុមហ៊ុនតុបតែងលម្អអគារ ក្រុមហ៊ុនផ្គត់ផ្គង់ ឬផលិត សម្ភារ:បរិក្ខារសំណង់ ក្រុមហ៊ុនគ្រឿងចក្រសំណង់ ក្រុមហ៊ុនរៀបចំដាក់បណ្តាញទឹក ភ្លើង និង មេកានិកមានសិទ្ធិសុំចូលជាសមាជិកសមាគម ដោយយល់ព្រមគោរពតាមលក្ខន្តិក: និងបទបញ្ជាផ្ទៃក្នុងរបស់សមាគម ។

សមាជិករបស់សមាគមមាន ៣ ប្រភេទ ៖

- សមាជិកកិត្តិយស
- សមាជិកស្ថាបនិក
- សមាជិកគាំទ្រ

**ប្រការ ១០. អំពីសមាជិកកិត្តិយស**

សមាជិកកិត្តិយសសំដៅដល់ឥស្សរជនដែលជួយជាគំនិត និងជួយសម្របសម្រួលការងាររបស់សមាគមឲ្យមានការរីកចំរើនលើវិស័យសំណង់ ។រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិកកិត្តិយសមួយរូបរបស់សមាគម ។

**ប្រការ ១១ . អំពីសមាជិកស្ថាបនិក**

សមាជិកស្ថាបនិក សំដៅដល់ប្រធានក្រុមហ៊ុនដែលរួមចំណែកផ្តួចផ្តើមគំនិតបង្កើតសមាគមនេះឡើង និងជួយឧបត្ថម្ភជាមធ្យោបាយផ្សេងៗ។

**ប្រការ ១២. អំពីសមាជិក គាំទ្រ**

សមាជិកគាំទ្រសំដៅដល់ក្រុមហ៊ុនដែលបានស្នើសុំចូលជាសមាជិកសមាគម និងយល់ព្រមគោរពតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សមាគម។

## ផ្នែកទី ២
## អំពីការបាត់បង់សមាជិកភាព

**ប្រការ ១៣. អំពីការបាត់បង់សមាជិកភាព**

ការបាត់បង់សមាជិកភាពសមាគមអាចកើតមានឡើងក្នុងករណីណាមួយដូចខាងក្រោម ៖

១- សុំលាលែងពីសមាជិកសមាគម ។

២-មិនគោរពតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចចិត្តផ្សេងៗរបស់មហាសន្និបាត និងគណៈកម្មាធិការប្រតិបត្តិរបស់សមាគម។ក្នុងករណីនេះសមាជិកប្រភេទនោះអាចត្រូវបាន បណ្តេញចេញដោយសម្លេង ២/៣ នៃគណៈកម្មាធិការប្រតិបត្តិរបស់សមាគម ។

៣-មានជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌណាមួយ ។

៤- ទទួលមរណៈភាព ។

៥- ក្ស័យធន ផ្អាកអាជីវកម្ម ឬបិទក្រុមហ៊ុន ។

# ជំពូកទី ៤
## អំពីសិទ្ធិ និងភារកិច្ចរបស់សមាជិកសមាគម

**ប្រការ ១៤ . អំពីសិទ្ធិរបស់សមាជិកសមាគម**

សមាជិកសមាគមមានសិទ្ធិបោះឆ្នោតឬឈរឈ្មោះឲ្យគេបោះឆ្នោតចូលក្នុងគណៈកម្មាធិការប្រតិបត្តិរបស់សមាគម ចូលរួមផ្តល់មតិយោបល់ក្នុងមហាសន្និបាតសមាគម និងចូលរួមគ្រប់សកម្មភាពសមាគម។ សមាជិកសមាគមមានសិទ្ធិទទួលបានវិញ្ញាបនប័ត្រសមាជិកសមាគមរួមទាំងផលប្រយោជន៍ពីការបណ្តុះបណ្តាលបង្កើនសមត្ថភាពវិជ្ជាជីវៈ និងបទពិសោធន៍ការងារសមាគម។

**ប្រការ ១៥**. អំពីកាតព្វកិច្ចរបស់សមាជិកសមាគម

សមាជិកសមាគម មានកាតព្វកិច្ច ៖

១- បង់វិភាគទានតាមការកំណត់របស់សមាគម

២- គោរពតាមលក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុងរបស់សមាគម

៣- ចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិរបស់សមាគម។

# ជំពូកទី ៥

# អំពីរចនាសម្ព័ន្ធដឹកនាំរបស់សមាគម

**ប្រការ ១៦**. អំពីរចនាសម្ព័ន្ធដឹកនាំ

ស.ស.ក មានរចនាសម្ព័ន្ធដឹកនាំដូចខាងក្រោម ៖

- មហាសន្និបាត
- គណៈកម្មាធិការប្រតិបត្តិ ។

## ផ្នែកទី ១

## អំពីមហាសន្និបាត ស.ស.ក

**ប្រការ ១៧**. អំពីមហាសន្និបាត ស.ស.ក

មហាសន្និបាត ស.ស.ក ជាស្ថាប័នដឹកនាំខ្ពស់បំផុតរបស់ ស.ស.ក។ មហាសន្និបាត ស.ស.ក រៀបចំធ្វើឡើងក្នុងមួយឆ្នាំម្តងនៅសប្តាហ៍ទី២ ខែធ្នូនៃឆ្នាំនីមួយៗដោយមានការចូលរួមពីសមាជិកទាំងអស់របស់ ស.ស.ក។

**ប្រការ ១៨**. អំពីមហាសន្និបាតសាមញ្ញ និងមហាសន្និបាតវិសាមញ្ញ

- មហាសន្និបាត ស.ស.ក មានពីរប្រភេទ គឺមហាសន្និបាតសាមញ្ញ និងមហាសន្និបាតវិសាមញ្ញ ។ មហាសន្និបាតសាមញ្ញធ្វើឡើងក្នុងមួយឆ្នាំម្តងតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិរបស់សមាគម ។
- មហាសន្និបាតវិសាមញ្ញអាចប្រព្រឹត្តិឡើងក្នុងករណីមានការចាំបាច់ដោយមានសំណូមពរពីសមាជិកសមាគមយ៉ាងតិច ១/៣ ឬមានសំណូមពរពីប្រធានគណៈកម្មាធិការប្រតិបត្តិរបស់សមាគម ។
- មហាសន្និបាតអាចដំណើរការបានលុះត្រាតែមានសមាជិកចូលរួមយ៉ាងតិច២/៣នៃសមាជិកទាំងអស់របស់ ស.ស.ក ។



នាយកដ្ឋានកិច្ចការនយោបាយ

**ប្រការ ១៩**. ភារកិច្ចរបស់មហាសន្និបាត

មហាសន្និបាតរបស់ ស.ស.ក មានភារកិច្ចដូចខាងក្រោម ៖

១-ពិនិត្យពិភាក្សានិងអនុម័តលើរបាយការណ៍បូកសរុបសកម្មភាពការងារនិងហិរញ្ញវត្ថុសមាគមប្រចាំឆ្នាំ និងទិសដៅការងារសមាគមនៅឆ្នាំខាងមុខ ។

២- បោះឆ្នោតជ្រើសរើសគណៈកម្មាធិការប្រតិបត្តិសម្រាប់អាណត្តិថ្មី ។

៣- អនុម័តបទបញ្ជាផ្ទៃក្នុងរបស់សមាគម និងក្រមសីលធម៌សម្រាប់អ្នកសាងសង់ ។

៤- អនុម័តលើការរំសាយសមាគម និងការចាត់ចែងទ្រព្យរបស់សមាគមនៅពេលដែលសមាគមត្រូវរំសាយ ។

**ប្រការ ២០**. អំពីសេចក្តីសម្រេចរបស់មហាសន្និបាត

សេចក្តីសម្រេចរបស់មហាសន្និបាតទាមទារឲ្យមានសម្លេងគាំទ្រ ៥0%+១សម្លេង នៃចំនួនសមាជិកចូលរួមមហាសន្និបាត ។

**ប្រការ ២១**. អំពីប្រធានដឹកនាំអង្គប្រជុំមហាសន្និបាត

ប្រធានគណៈកម្មាធិការប្រតិបត្តិរបស់សមាគមជាប្រធានដឹកនាំអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិ និងមហាសន្និបាតរបស់សមាគម។ក្នុងករណីប្រធានអវត្តមានអនុប្រធានគណៈកម្មាធិការប្រតិបត្តិអាចធ្វើជាប្រធានដឹកនាំអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិ តែមិនអាចធ្វើជាប្រធានអង្គប្រជុំមហាសន្និបាតរបស់សមាគមបានទេ លើកលែងតែមហាសន្និបាតយល់ព្រមដោយមានសម្លេងគាំទ្រភាគច្រើនដាច់ខាត នៃសមាជិកមហាសន្និបាត ។

## ផ្នែកទី ២
## អំពីគណៈកម្មាធិការប្រតិបត្តិ

**ប្រការ ២២**. អំពីសមាសភាពគណៈកម្មាធិការប្រតិបត្តិ

គណៈកម្មាធិការប្រតិបត្តិរបស់សមាគមត្រូវបានជ្រើសរើសចេញពីសមាជិករបស់សមាគមតាមរយៈការបោះឆ្នោតក្នុងមហាសន្និបាតសម្រាប់រយៈពេល ៣ ឆ្នាំ។

គណៈកម្មាធិការប្រតិបត្តិ មានសមាសភាពយ៉ាងតិច ១១ រូប ៖

| | |
|---|---|
| - ប្រធានគណៈកម្មាធិការប្រតិបត្តិ (ប្រធានសមាគម) | ០១ រូប |
| - អនុប្រធាន | ០២ រូប |
| - អគ្គលេខាធិការ | ០១ រូប |
| - អគ្គលេខាធិការរង | ០២ រូប |
| - សមាជិក | ០៥ រូប |



នាយកដ្ឋានកិច្ចការនយោបាយ

**ប្រការ ២៣.** ភារកិច្ចរបស់គណៈកម្មាធិការប្រតិបត្តិ

គណៈកម្មាធិការប្រតិបត្តិរបស់សមាគមដែលមានតួនាទីជាអ្នកដឹកនាំសកម្មភាពការងារអចិន្ត្រៃយ៍របស់សមាគមមានភារកិច្ចដូចតទៅ ៖

១- អនុវត្តរាល់សេចក្តីសម្រេចរបស់មហាសន្និបាត ។

២- ធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារ និងហិរញ្ញវត្ថុរបស់សមាគម ជូនមហាសន្និបាតអនុម័ត។

៣- រៀបចំគម្រោងផែនការការងារផ្សេងៗក្នុងកិច្ចដំណើរការ និងអភិវឌ្ឍសមាគម។

៤- អនុវត្តនូវរាល់សកម្មភាពការងារ ដើម្បីសម្រេចគោលដៅ និងគោលបំណងរបស់សមាគមដូចមានចែងក្នុងប្រការ ៥ និងប្រការ ៦ នៃលក្ខន្តិកៈសមាគម។

៥- ធ្វើទំនាក់ទំនងជាមួយសមាគមអ្នកសាងសង់អាស៊ាន និងអន្តរជាតិ ជាមួយអង្គការជាតិ-អន្តរជាតិ រដ្ឋាភិបាលនិងសមាគមនានាដើម្បីស្វែងរកប្រភពធនធានដែលជាប្រ យោជន៍ និងអភិវឌ្ឍសមាគម។

៦- គ្រប់គ្រងចំណូលចំណាយរបស់សមាគម។

៧- រៀបចំបទបញ្ជាផ្ទៃក្នុងរបស់សមាគម និងក្រមសីលធម៌សម្រាប់អ្នកសាងសង់។

៨- តាមដានត្រួតពិនិត្យ និងវាយតម្លៃនូវរាល់សកម្មភាពការងារផ្សេងៗ និងគម្រោងនានារបស់សមាគម។

៩- បំពេញភារកិច្ចផ្សេងៗទៀតដែលមហាសន្និបាតបានប្រគល់ជូន ។

**ប្រការ ២៤.** អំពីការប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ

គណៈកម្មាធិការប្រតិបត្តិត្រូវធ្វើការប្រជុំក្នុងមួយខែម្តងនិងអាចធ្វើការប្រជុំវិសាមញ្ញទៅតាមការចាំបាច់ ។ ការប្រជុំរបស់គណៈកម្មាធិការ ធ្វើឡើងដើម្បីត្រួតពិនិត្យឡើងវិញនូវរាល់សកម្មភាពការងារ និងហិរញ្ញវត្ថុរបស់សមាគមនាពេលកន្លងមក និងលើកទិសដៅការងារ និងហិរញ្ញវត្ថុសំរាប់ពេលខាងមុខ ។ អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិអាចប្រព្រឹត្តិទៅបានលុះត្រាតែមានសមាជិកចូលរួមយ៉ាងតិច២/៣ ហើយសេចក្តីសម្រេចនានារបស់គណៈកម្មាធិការដែលទទួលយកជាផ្លូវការនោះ ត្រូវមានសម្លេងគាំទ្រភាគច្រើនដាច់ខាត នៃសមាជិកចូលរួមប្រជុំទាំងអស់។

**ប្រការ ២៥.** អំពីផ្នែកនានារបស់គណៈកម្មាធិការប្រតិបត្តិ

គណៈកម្មាធិការប្រតិបត្តិរបស់សមាគមអាចបង្កើតផ្នែកផ្សេងៗដើម្បីជាជំនួយការបច្ចេកទេស ។ ប្រធានផ្នែកនីមួយៗ ជាសមាជិករបស់គណៈកម្មាធិការប្រតិបត្តិរបស់សមាគម ។

**ប្រការ ២៦.** ប្រធានគណៈកម្មាធិការប្រតិបត្តិ

ប្រធានគណៈកម្មាធិការប្រតិបត្តិសមាគម គឺជាប្រធានសមាគម និងជាតំណាងស្របច្បាប់



ការិយាល័យចុះបញ្ជីកិច្ចការនយោបាយ

របស់សមាគម ដែលមានតួនាទីជាអ្នកទទួលបន្ទុកការងារ និងទទួលខុសត្រូវរួមនូវរាល់សកម្មភាពរបស់សមាគម ។

**ប្រការ ២៧.** អនុប្រធានគណៈកម្មាធិការប្រតិបត្តិ

អនុប្រធានគណៈកម្មាធិការប្រតិបត្តិសមាគម គឺជាអនុប្រធានសមាគម និងមានភារកិច្ចជួយកិច្ចការប្រធានគណៈកម្មាធិការតាមការកំណត់របស់ប្រធាន។ អនុប្រធានគណៈកម្មាធិការមានតួនាទីជំនួសប្រធាន ពេលប្រធានគណៈកម្មាធិការអវត្តមានក្នុងឋានៈជាប្រធានស្តីទី ដោយត្រូវមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធាន។

**ប្រការ ២៨.** អគ្គលេខាធិការនៃគណៈកម្មាធិការប្រតិបត្តិសមាគម

អគ្គលេខាធិការនៃគណៈកម្មាធិការប្រតិបត្តិសមាគមមានតួនាទីជាអ្នកសម្របសម្រួលនិងទំនាក់ទំនងការងារទាំងអស់របស់គណៈកម្មាធិការ ទាំងខាងក្នុងសមាគម និងខាងក្រៅសមាគម។ អគ្គលេខាធិការនៃគណៈកម្មាធិការប្រតិបត្តិសមាគមមានភារកិច្ចរៀបចំផែនការសកម្មភាពការងារនានារបស់គណៈកម្មាធិការ និងទទួលខុសត្រូវលើការងាររដ្ឋបាលហិរញ្ញវត្ថុ និងរបាយការណ៍ប្រជុំរបស់គណៈកម្មាធិការ និងរបាយការណ៍បូកសរុបសកម្មភាពការងារប្រចាំឆ្នាំរបស់គណៈកម្មាធិការប្រតិបត្តិរបស់សមាគម ។

# ជំពូកទី ៦

## អំពីបទបញ្ជាផ្ទៃក្នុងរបស់សមាគម និងក្រមសីលធម៌សម្រាប់អ្នកសាងសង់

**ប្រការ ២៩.** ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់សមាគម

- គណៈកម្មាធិការប្រតិបត្តិរបស់សមាគម ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងឱ្យបានលម្អិតក្រោយពេលមានការអនុម័តលក្ខន្តិកៈនេះរួចជាស្ថាពរ ។
- បទបញ្ជាផ្ទៃក្នុងត្រូវចែងជាអាទិ៍ អំពីសិទ្ធិ កាតព្វកិច្ច ការការពារ និងការ ទទួល ខុសត្រូវរបស់សមាជិកសមាគម អំពីការបង់វិភាគទានរបស់សមាជិកជូនសមាគម និងអំពីនីតិវិធីនៃការធ្វើសេចក្តីសម្រេចចិត្តរបស់សមាគម ពាក់ព័ន្ធនឹងការកែសម្រួលបទបញ្ជាផ្ទៃក្នុង របស់សមាគម ។ល។
- បទបញ្ជាផ្ទៃក្នុងមិនត្រូវចែងផ្ទុយនឹងបទប្បញ្ញត្តិ និងច្បាប់ជាធរមានឡើយ។

**ប្រការ ៣០.** ក្រមសីលធមិសម្រាប់អ្នកសាងសង់

គណៈកម្មាធិការប្រតិបត្តិរបស់សមាគមត្រូវរៀបចំក្រមសីលធិមសម្រាប់អ្នកសាងសង់ឱ្យបានលម្អិតក្រោយពេលមានការអនុម័តលក្ខន្តិកៈនេះរួចជាស្ថាពរ ។

ក្រមសីលធមិត្រូវចែងជាអាទិ៍អំពី :

- ការបំពេញវិជ្ជាជីវៈជាអ្នកសាងសង់ប្រកបដោយជំនាញនៅគ្រប់ដំណាក់កាលទាំងពេលដេញថ្លៃ ពេលសាងសង់ និងក្រោយការសាងសង់

- ការបំពេញវិជ្ជាជីវៈជាអ្នកសាងសង់ដែលស្មោះត្រង់ និងត្រឹមត្រូវចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់ និងនៅគ្រប់ដំណាក់កាល
- ការចូលរួមដេញថ្លៃសាងសង់ ក្នុងករណីដែលក្រុមហ៊ុនខ្លួនមានបំណងចង់ទទួលការងារប៉ុណ្ណោះ
- មិនអនុញ្ញាតឱ្យមានការប្រកួតប្រជែង មិនស្មោះត្រង់ក្នុងការដេញថ្លៃ
- ការគាំពារដល់កម្មករ ឬបុគ្គលិកដែលបម្រើការងារនៅការដ្ឋានសំណង់
- ការកំណត់ពីគោលនយោបាយរបស់ក្រុមហ៊ុនសាងសង់ ចំពោះគណនេយ្យភាពសង្គម។

## ជំពូកទី ៧

## អំពីការធ្វើវិសោធនកម្មលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សមាគម

**ប្រការ ៣១**. ការធ្វើវិសោធនកម្ម លក្ខន្តិកៈ និង/ឬបទបញ្ជាផ្ទៃក្នុងសមាគម

- មានតែមហាសន្និបាតស.ស.កតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការធ្វើវិសោធន-កម្មលក្ខន្តិកៈ និង/ឬបទបញ្ជាផ្ទៃក្នុងរបស់សមាគមតាមរយៈការស្នើសុំពីសមាជិករបស់សមាគមយ៉ាងតិចចំនួន២/៣ឡើងទៅ
- ក្នុងករណីចាំបាច់គណៈកម្មាធិការប្រតិបត្តិរបស់សមាគមដែលមានសមាជិកចំនួនយ៉ាងតិច ២/៣មានសិទ្ធិស្នើសុំធ្វើវិសោធនកម្មលក្ខន្តិកៈនិង/ឬ បទបញ្ជាផ្ទៃក្នុងរបស់សមាគម ។

**ប្រការ ៣២**. ការចូលជាធរមាននៃលក្ខន្តិកៈ និង/ឬបទបញ្ជាផ្ទៃក្នុងថ្មីរបស់សមាគម

លក្ខន្តិកៈនិង/ឬបទបញ្ជាផ្ទៃក្នុងថ្មីរបស់សមាគមត្រូវចូលជាធរមាន ក្នុងរយៈពេលមួយខែក្រោយពេលធ្វើវិសោធនកម្ម។ អគ្គលេខាធិការនៃគណៈកម្មាធិការប្រតិបត្តិរបស់សមាគមត្រូវផ្សព្វផ្សាយលក្ខន្តិកៈនិង/ឬបទបញ្ជាផ្ទៃក្នុងថ្មីដែលបានធ្វើវិសោនកម្មជូនគ្រប់សមាជិកទាំងអស់ ។

## ជំពូកទី ៨

## អំពីការរំលាយសមាគម

**ប្រការ ៣៣**. ការរំលាយសមាគម

ក្នុងករណីដែល ស.ស.ក ត្រូវបានរំលាយ ទ្រព្យសម្បត្តិទាំងអស់របស់សមាគមត្រូវផ្តល់អាទិភាពក្នុងការទូទាត់បំណុលស្របច្បាប់របស់សមាគម។ ក្រោយទូទាត់បំណុលស្របច្បាប់រួចហើយ ទ្រព្យសម្បត្តិដែលនៅសល់ត្រូវបានគណៈកម្មាធិការប្រតិបត្តិរបស់សមាគមចាត់ចែងផ្ទេរទ្រព្យសម្បត្តិទាំងនោះជូនទៅកាកបាទក្រហមកម្ពុជាឬជូនទៅអង្គការមនុស្សធម៌ស្របច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី ៩

## អន្តរប្បញ្ញត្ត

**ប្រការ ៣៤**. ការអនុម័តសេចក្តីព្រាងលក្ខន្តិកៈ

សេចក្តីព្រាងលក្ខន្តិកៈសមាគមអ្នកសាងសង់កម្ពុជានឹងត្រូវបានពិនិត្យពិភាក្សា និងអនុម័ត ដោយមហាសន្និបាតលើកទី១របស់ ស.ស.ក។

**ប្រការ ៣៥**. ការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការប្រតិបត្តិអាណត្តិទី១

មហាសន្និបាតលើកទី១របស់**ស.ស.ក**ឬមហាសន្និបាតបង្កើតសមាគម**ស.ស.ក** ត្រូវបោះឆ្នោតជ្រើសរើសគណៈកម្មាធិការប្រតិបត្តិរបស់សមាគមអាណត្តិទី១ ក្នុងចំណោមសមាជិកស្ថាបនិករបស់សមាគមដែលមានតួនាទីដឹកនាំសកម្មភាពការងារអចិន្ត្រៃយ៍របស់សមាគម ។ របៀបបោះឆ្នោតជ្រើសរើសគណៈកម្មាធិការប្រតិបត្តិរបស់សមាគមអាណត្តិទី១នេះ អាស្រ័យដោយមហាសន្និបាត លើកទី១ ជាអ្នកកំណត់។

# ជំពូកទី ១០

## អវសានប្បញ្ញត្ត

**ប្រការ ៣៦**. ការចូលជាធរមាន

លក្ខន្តិកៈរបស់ **ស.ស.ក**ត្រូវបានអនុម័តដោយមហាសន្និបាតលើកទី១នៃ **ស.ស.ក** នាថ្ងៃទី០៦ ខែ តុលា ឆ្នាំ ២០១១ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១១

ជ. គណៈកម្មាធិការប្រតិបត្តិ ស.ស.ក

**ប្រធាន**

នាយកដ្ឋានកិច្ចការនយោបាយ

ប្រធាន